**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍**

# របាយការណ៍កិច្ចប្រជុំ
# ក្រុមប្រឹក្សាបច្ចេកទេសអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ លើកទី៨

១. **ថ្ងៃ ខែ ឆ្នាំ៖** ថ្ងៃសុក្រ ៩កើត ខែស្រាពណ៍ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី២៥ ខែសីហា ឆ្នាំ២០២៣

២. **ទីកន្លែង៖** នៅអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងតាមប្រព័ន្ធអនឡាយ(Zoom)

៣. ប្រធាន **និងសមាសភាពចូលរួម ៖**

៣.១ ប្រធានអង្គប្រជុំ **ឯកឧត្តមបណ្ឌិត ឈឹម ឃិនដារ៉េត** អគ្គលេខាធិការអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

៣.២ សមាសភាពចូលរួមមាន សមាជិក សមាជិកាថ្នាក់បច្ចេកទេសអន្តរក្រសួង ស្ថាប័ន រាជធានី ខេត្ត និងអង្គការពាក់ព័ន្ធ ដែលចូលរួមផ្ទាល់ចំនួន២៣រូប និងតាមប្រព័ន្ធអនឡាយចំនួន៤១រូប សរុបចំនួន៦៤រូប។

៤. របៀបវារៈ៖

៤.១-មតិស្វាគមន៍ និងគោលបំណងនៃកិច្ចប្រជុំដោយ **ឯកឧត្តមបណ្ឌិត ឈឹម ឃិនដារ៉េត** អគ្គលេខាធិការអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងជាប្រធានក្រុមប្រឹក្សាបច្ចេកទេស។

៤.២-បទបង្ហាញស្តីពីការត្រៀមយុទ្ធនាការផ្តល់ប័ណ្ណសមធម៌ជូនដល់បុគ្គលបម្រើសេវាកម្សាន្តក្រៅប្រព័ន្ធ នៅតាមបណ្តារខេត្ត ដោយ **ឯកឧត្តម កែវ អ៊ូលី** ប្រធាននាយកដ្ឋានអត្តសញ្ញាណកម្មគ្រួសារក្រីក្រ ក្រសួងផែនការ។

៤.៣-ពិភាក្សារលើឧបសគ្គមួយចំនួនក្នុងការប្រមូលបញ្ជីឈ្មោះ និងយុទ្ធនាការផ្តល់ប័ណ្ណ សមធម៌ជូនដល់បុគ្គលបម្រើសេវាកម្សាន្តក្រៅប្រព័ន្ធ នៅតាមបណ្តារ រាជធានី ខេត្ត។

៤.៤-មតិបូកសរុប និងបិទកម្មវិធីដោយ **ឯកឧត្តមបណ្ឌិត ឈឹម ឃិនដារ៉េត** អគ្គលេខាធិការ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងជំងឺអេដស៍។

៥. លទ្ធផល ៖

**៥.១** ជាកិច្ចចាប់ផ្ដើម **ឯកឧត្តមបណ្ឌិត ឈឹម ឃិនដារ៉េត** អគ្គលេខាធិការ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងជាប្រធានក្រុមប្រឹក្សាបច្ចេកទេស បានទទួលការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពី **ឯកឧត្តមទេសរដ្ឋមន្ត្រី អៀង មូលី** ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានដឹកនាំកិច្ចប្រជុំក្រុមប្រឹក្សាបច្ចេកទេសលើកទី៨ ឆ្នាំ២០២៣ របស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។

ដំណើរការនៃកិច្ចប្រជុំមាន៖

**ឯកឧត្តមបណ្ឌិត** អគ្គលេខាធិការ បានមានប្រសាសន៍ជូនអង្គប្រជុំឱ្យបានជ្រាបថា កិច្ចប្រជុំថ្ងៃនេះ បានផ្ដោតលើការពិនិត្យ និងពិភាក្សា ពិភាក្សាលើឧបសគ្គមួយចំនួនក្នុងការប្រមូលបញ្ជីឈ្មោះ និងយុទ្ធនាការផ្ដល់ប័ណ្ណ សមធម៌ជូនដល់បុគ្គលបម្រើសេវាកម្សាន្តក្រៅប្រព័ន្ធ នៅតាមបណ្ដារ រាជធានី ខេត្ត។

**៥.២** បទបង្ហាញស្ដីពីការត្រៀមយុទ្ធនាការផ្ដល់ប័ណ្ណសមធម៌ជូនដល់បុគ្គលបម្រើសេវាកម្សាន្តក្រៅប្រព័ន្ធ នៅតាមបណ្ដារខេត្ត ដោយ **ឯកឧត្តម កែវ អ៊ីលី** ប្រធាននាយកដ្ឋានអត្តសញ្ញាណកម្មគ្រួសារក្រីក្រ ក្រសួងផែនការ។

យោងតាមចំណារឯកភាពដ៏ខ្ពង់ខ្ពស់របស់ **សម្ដេចអគ្គមហាសេនាបតី តេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី** នៃព្រះរាជាណាចក្រកម្ពុជា លើលិខិត លេខ៥៥៤៣ សហវ.លស.អកគ ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០២៣ របស់ក្រសួង សេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្ដីពីរបាយការណ៍វឌ្ឍនភាពនៃការរៀបចំយន្តការ និងនីតិវិធីផ្ដល់បណ្ណមូលនិធិសមធម៌សុខាភិបាល (ម.ស.ស) ចេញដោយ បេឡាជាតិសន្តិសុខសង្គម សម្រាប់បុគ្គលបម្រើការក្នុងសេវាកម្សាន្តទេសចរណ៍នៃសេដ្ឋកិច្ចក្រៅប្រព័ន្ធពិសេសស្ត្រី។ ក្នុងរបាយការណ៍នោះ ក្រសួងផែនការក៏មានតួនាទីរៀបចំយុទ្ធនាការសម្ភាសន៍ ផ្ដល់បណ្ណសមធម៌ជូនបុគ្គល ឬគ្រួសារមានសមាជិកបម្រើការក្នុងសេវាកម្សាន្តទេសចរណ៍ នៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ ដែលមានការលំបាកផ្នែកជីវភាព តែនៅមិនទាន់បានទទួលបណ្ណសមធម៌ដែរ។ បន្ទាប់ពីយុទ្ធនាការនេះចប់ ក្រុមការងារឃុំ សង្កាត់ ត្រូវបន្តអនុវត្តការងារនេះជាមួយដំណើរការអនុវត្តនីតិវិធីកំណត់អត្តសញ្ញាណគ្រួសារក្រីក្រ និងគ្រួសារងាយរងហានិភ័យ។

ក្រសួងផែនការ បានរៀបចំលិខិតជូនដំណឹងលេខ ០៥៤៥ ផក ជម្រាបជូនឯកឧត្តម លោកជំទាវ អភិបាលនៃគណៈ អភិបាលរាជធានី ខេត្ត ដើម្បីបន្តអនុវត្តនីតិវិធីការកំណត់អត្តសញ្ញាណគ្រួសារក្រីក្រ និងគ្រួសារងាយរងហានិភ័យ និងរៀបចំសម្ភាសន៍បុគ្គល ឬគ្រួសារមានសមាជិកបម្រើការក្នុងសេវាកម្សាន្តទេសចរណ៍ នៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ ដែលមានការលំបាកផ្នែកជីវភាព។ ក្រសួងក៏បានរៀបចំសេចក្ដីណែនាំស្ដីពីយុទ្ធនាការសម្ភាសន៍ផ្ដល់បណ្ណសមធម៌ជូនដល់បុគ្គលឬគ្រួសារ មានសមាជិកបម្រើការក្នុងសេវាកម្សាន្តទេសចរណ៍ នៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ ដែលមានការលំបាកផ្នែកជីវភាព

- ជាក់ស្ដែងនៅថ្ងៃទី១១ និង១២ ខែសីហា ឆ្នាំ២០២៣កន្លងទៅ បានធ្វើការសម្ភាសន៍សាកល្បងនូវគោល ដៅពីរ គឺ សង្កាត់វត្តភ្នំ និងសង្កាត់ស្រះចក ក្នុងខណ្ឌដូនពេញ
- មន្ទីរផែនការរាជធានី-ខេត្ត ដោយមានការសហការពីក្រុមបណ្ដាញ និងអាជ្ញាធរមូលដ្ឋាន បាននឹងកំពុង ត្រៀមរៀបចំយុទ្ធនាការជាបន្តបន្ទាប់ នៅតាមខេត្តក្រុង/ស្រុក/ខណ្ឌគោលដៅរៀងៗខ្លួន។

ចំពោះបញ្ហាប្រឈមដែលបានជួបប្រទះ

- ខ្វះព័ត៌មានពីក្រុមគោលដៅ(បញ្ជីឈ្មោះក្រុមគោលដៅ)
- មិនមានឯកសារបញ្ជាក់ពីការស្នាក់នៅក្នុងមូលដ្ឋានជាមុន ដែលតម្រូវឲ្យអាជ្ញាធរមូលដ្ឋានត្រូវចំណាយ ពេលរៀបចំឯកសារបញ្ជាក់ភ្លាមៗ អំឡុងពេលនៃយុទ្ធនាការ បុគ្គលមួយចំនួនមានឈ្មោះក្នុងបញ្ជី ប៉ុន្តែមិនបានមកចូលរួមសម្ភាសន៍
- សង្កាត់ហាក់មិនចង់ទទួលស្គាល់បុគ្គលមួយចំនួន ដែលគាត់ផ្លាស់ទីលំនៅញឹកញាប់
- សៀវភៅស្នាក់នៅតែមួយ ប៉ុន្តែមានគ្រួសារពីរ ឬច្រើន
- បុគ្គលមួយចំនួនមិនហ៊ានចូលរួមក្នុងយុទ្ធនាការដោយសារ ខ្លាចបែកធ្លាយអត្តសញ្ញាណរបស់គាត់

**ឯកឧត្តមបណ្ឌិត ឈឹម យិនដារ៉េត** បានធ្វើការបញ្ជាក់ថា ការប៉ាន់ស្មានមេរោគអេដស៍ថ្មី បានបង្ហាញថា ការកើនឡើងសមាមាត្រនៃការឆ្លង មេរោគអេដស៍ថ្មីគឺស្ថិតក្នុងចំណោមបុរស និងក្មេងប្រុស ពួកគេមានចំនួន៧៩% នៃការឆ្លងមេរោគអេដស៍ថ្មីទាំងអស់ក្នុងឆ្នាំ២០២២។ តាមចំនួនប្រជាជន៨៣% នៃការឆ្លងមេរោគអេដស៍ថ្មី សរុបគឺស្ថិតក្នុងចំណោម ប្រជាជនគន្លឹះ បុរសរួមភេទជាមួយបុរស ស្ត្រីបំប្លែងភេទ អ្នកដែលប្រើប្រាស់និងចាក់ថ្នាំញៀន និងដៃគូផ្លូវភេទរបស់ពួកគេ។ សមិទ្ធិផលរបស់ប្រទេសកម្ពុជា ត្រូវបានចាត់ទុកជាគំរូ ក្នុងការសម្រេចបានខ្ពស់បំផុតនូវអត្រាទទួលសេវាព្យាបាល និងអត្រាកាត់បន្ថយមេរោគមកកម្រិតទាបបំផុតក្នុងចំណោមអ្នកផ្ទុកមេរោគអេដស៍។

នាឱកាសនោះ **ឯកឧត្តមបណ្ឌិត** អគ្គលេខាធិការប្រធានអង្គប្រជុំបានបញ្ជាក់ថា នឹងទទួលយកសំណើនៅក្នុងកិច្ចប្រជុំដែលបានលើកឡើងនឹងពិភាក្សាជាមួយក្រុមការងារ ដោយយើងមិនអាចធ្វើបានគ្រប់គ្នាទេ យើងត្រូវជ្រើសរើសថាតើគួរធ្វើទៅលើក្រុមណាដែលងាយប្រឈម។ ឯកឧត្តម ក៏បានបន្តថា ជាក់ស្តែងប្រទេសកម្ពុជាយើង នៅមានឧបសគ្គក្នុងការសម្រេចឱ្យបាននូវគោលដៅ៩៥ ទី១ដែលនៅឆ្ងាយពីគោលដៅកំណត់ និងដែលទាមទារឱ្យយើងទាំងអស់គ្នាត្រូវបន្តរួមគ្នា រកវិធីសាស្ត្រប្រកបដោយប្រសិទ្ធភាពផ្សេងៗទៀត ដើម្បីសម្រេចគោលដៅនេះ។

ចុងបញ្ចប់ **ឯកឧត្តមបណ្ឌិត** អគ្គលេខាធិការ ប្រធានអង្គប្រជុំក៏បានបន្ថែមថា ការងារប្រយុទ្ធនឹងមេរោគអេដស៍ នៅមានរយៈពេលយូរទៅមុខទៀត ដែលតម្រូវឱ្យយើងបន្តធ្វើការរួមគ្នា រវាងអ្នកធ្វើគោលនយោបាយ និងយុទ្ធសាស្ត្រ អ្នកផ្តល់សេវា និងអ្នករងផលប៉ះពាល់។ម្យ៉ាងទៀតត្រូវពង្រឹងភាពជាម្ចាស់ ចាំបាច់ត្រូវមានការផ្លាស់ប្តូរ ដើម្បីពិនិត្យលទ្ធភាពបង្កើនការផ្តល់ថវិកាជាតិ ដោយឡែកដល់ថ្នាក់ក្រោមជាតិ ដែលរួមមានគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍រាជធានី ខេត្ត គណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ក្រុង ស្រុក ខណ្ឌ និងគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ឃុំ សង្កាត់ ដើម្បីបង្កើនបទអន្តរាគមន៍ឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍ឱ្យចំលើការងារជាអាទិភាព ពិសេសក្រុមប្រឈមមុខខ្ពស់ និងទីតាំងអាទិភាពដែលមានការចម្លងច្រើនដោយប្រើអន្តរាគមន៍ដែលមានប្រសិទ្ធភាពខ្ពស់ និងជាបណ្តើរៗជានាចីរភាព និងមានភាពធន់នៃប្រព័ន្ធជាតិឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍។

សម្រាប់កិច្ចប្រជុំលើកទី៩នឹងកំណត់យក នៅថ្ងៃសុក្រ ៨កើត ខែភទ្របទ ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦ ត្រូវនឹងថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០២៣ នៅអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងតាមប្រព័ន្ធអនឡាញ(Zoom)៕

ថ្ងៃព្រហស្បតិ៍ ខែស្រាពណ៍ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០២៣

**បានពិនិត្យត្រឹមត្រូវ**

**ប្រធាននាយកដ្ឋានទាក់ទង និងចលនាប្រភពធនធាន**

អ្នកធ្វើរបាយការណ៍

ប្រធានអង្គប្រជុំ

**បណ្ឌិត ឈឹម ឃិនដារ៉េត**